**គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស**

**COMMITTEE FOR ELECTION RIGHTS OF OVERSEAS CAMBODIANS (THE CEROC)**

**Email: board@khmeroversea.info, www.khmeroversea.info**


# សេចក្តីថ្លែងការណ៍

## ប្រារព្ធថ្ងៃទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ

**សូមគោរពបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា!**

ថ្ងៃនេះជាទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ នាងខ្ញុំតាងនាមគណកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេសឬជីស៊ីរ៉ុក មានកិត្តិយសនិងសូមកោតសរសើរដល់ការលះបង់និងការស្រឡាញ់ ជាតិមាតុភូមិរបស់បងប្អូនទាំងអស់ដែលមានវត្តមាននៅថ្ងៃនេះ។

យើងទាំងអស់គ្នាមានជំនឿជាផ្លុងមួយថា ដរាបណាប្រទេសកម្ពុជាគ្មានលទ្ធិប្រជាធិបតេយ្យ គ្មាននីតិរដ្ឋ គ្មានការគោរពសិទ្ធិមនុស្ស ដូចដែលយើងឃើញការវិវត្តន៍ចុងក្រោយក្រោមការដឹកនាំរបស់លោកហ៊ុន-សែន ដរាបនោះកម្ពុជាគ្មានទេសន្តិភាពពិតប្រាកដ គ្មានទេការអភិវឌ្ឍន៍ពិតប្រាកដ គ្មានទេអធិបតេយ្យជាតិពិតប្រាកដ គ្មានទេយុត្តិធម៌ និងគ្មានទេសាមគ្គីជាតិជាផ្លុងមួយពិតប្រាកដ។

យើងត្រូវការការបោះឆ្នោតមួយដែលមានន័យពិតប្រាកដ ដែលយើងអាចទទួលយកបានទាំងអស់គ្នា។ ការរំលាយគណបក្សសង្គ្រោះជាតិ ការយកកៅអីសភានិងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់គណបក្សសង្គ្រោះជាតិទៅចែកអោយបក្សផ្សេង គឺស្មើនឹងការជាន់ឈ្លីប្រជាពលរដ្ឋអ្នកបោះឆ្នោតជិតកន្លះប្រទេស ជាការរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា និងជាការរំលោភលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស២៣ តុលា ឆ្នាំ១៩៩១។ ការបោះឆ្នោតព្រឹទ្ធិសភាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨និងការបោះឆ្នោតជាតិថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខត្រូវតែមានគណបក្សសង្គ្រោះជាតិចូលរួមទើបសហគមជាតិនិងអន្តរជាតិទទួលស្គាល់ថាស្របច្បាប់និងយកជាការបាន។

យើងខ្ញុំដែលជាប្រជាពលរដ្ឋខ្មែររស់នៅនាយសមុទ្រទាំងអស់ដែលមានចំនួនដល់ទៅ៣លាននាក់នៅតែទាមទារសិទ្ធិបោះឆ្នោតដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនិងសេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ អោយខាងតែបាន។

*ជយោ លទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋនៅកម្ពុជា!*

*ជយោ ស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសអមតៈ!*

*ជយោ កំឡាំងសាមគ្គីរបស់ប្រជាពលរដ្ឋខ្មែរនៅក្រៅប្រទេស-ក្នុងប្រទេសទាំងអស់!*

ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៧

Committee for Election Rights of Overseas Cambodians (The CEROC)